**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គភាពសារព័ត៌មាន**

**ធីញូស៍ដេលី | THY News Daily**

*លេខ* ………………… **T.N.D**

# កិច្ចសន្យាការងារក្រៅម៉ោង

*កិច្ចព្រមព្រៀងនេះធ្វើឡើង*

**រវាង**

*ឈ្មោះ* **ហេង សុធីរ** *ភេទប្រុស អាយុ........ឆ្នាំ អាស័យដ្ឋានបច្ចុប្បន្នៈ ក្រុម២៤ ភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប តួនាទីជាៈ អគ្គនាយក និងចាងហ្វាង នៃអង្គភាពសារព័ត៌មានធីញូស៍ដេលី។ ហៅថា* ***ភាគី ក*** *។*

**និង**

*ឈ្មោះ..............................................ភេទ...........អាយុ.........ឆ្នាំ អាស័យដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ.......... ផ្លូវ............ភូមិ......................ឃុំ/សង្កាត់....................ក្រុង/ស្រុក/ខណ្ឌ........................រាជធានី/ខេត្ត...................... ដែលមានតួនាទីជា ភ្នាក់ងារយកព័ត៌មាន។ ហៅថា* ***ភាគី ខ*** *។*

*យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ អង្គភាពសារព័ត៌មានធីញូស៍ដេលី ។*

**សម្រេច**

**ភារកិច្ចរបស់ ភាគី ក ៖**

*១. ធានានូវភាពត្រឹមត្រូវរបស់ អង្គភាពសារព័ត៌មានធីញូស៍ដេលី ស្របទៅតាមច្បាប់របបសារព័ត៌មាន ឆ្នាំ១៩៩៥ និងច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ។*

*២. ត្រូវមានការលើកទឹកចិត្ត ជាកម្រៃសេវាដើងសារតាមលទ្ធភាពជាក់ស្តែង ក្នុងករណីដែល ភាគី ខ បាន ខិតខំយកព័ត៌មានផ្តល់មកឲ្យអង្គភាពចុះផ្សាយ ហើយទទួលបានការឧបត្ថម្ភ* **(Sponsor)** *ពីក្រុមហ៊ុន ឬស្ថាប័នណាមួយ ។*

*៣. ក្នុងករណីចាំបាច់ ឬពិសេសណាមួយត្រូវផ្តល់នូវគ្រឿងបរិក្ខារបច្ចេកទេសទៅឲ្យភាគី ខ សម្រាប់បម្រើឲ្យការយក ឬផ្សាយព័ត៌មាននោះ ។*

**ភារកិច្ចរបស់ ភាគី ខ ៖**

*១. គ្មានការលួចបន្លំ ឬកេងប្រវ័ញ្ចអ្វីមួយពីស្ថាប័ន ។*

*២. ធ្វើការដោយអត់ធ្មត់ ស្មោះត្រង់ សុទិដ្ឋិនិយមមិនឆេវឆាវ និងមិនជេរស្តីប្រមាថលើអ្នកដទៃ លើក្រុមការងារក្នុងអង្គភាព ពិសេសលើថ្នាក់ដឹកនាំ ។*

*៣. រាល់ការសុំច្បាប់ឈប់សំរាកត្រូវរាយការណ៍អោយភាគី (ក) ដឹងជាមុនយ៉ាងហោចណាស់ ៣ថ្ងៃ ។*

*៤. មានសាមគ្គីភាព ចេះយោគយល់អធ្យាស្រ័យគ្នាក្នុងពេលបំរើការងារ ។*

៥. ពេលចុះយកព័ត៌មាននៅក្នុងមូលដ្ឋានក្រោមការស្នើសុំពីប្រភពផ្តល់អោយ ត្រូវរាយការណ៍ជាបន្ទាន់មកចាងហ្វាង ឬគណៈគ្រប់គ្រង ឲ្យបានដឹងជាមុន ។
៦. រក្សាការសម្ងាត់របស់ប្រភពព័ត៌មានផ្តល់មកកាន់អង្គភាព និងការសម្ងាត់របស់អង្គភាព ។
៧. ប្រកាន់ភ្ជាប់នូវវប្បធម៌ការសន្ទនាគ្នា ដើម្បីរកដំណោះស្រាយពេលមានបញ្ហា ( ជៀសវាងអំពើហិង្សា) ។
៨. ក្នុងករណីគ្រឿងឧបករណ៍ប្រើប្រាស់មានបញ្ហាអ្វីមួយ ត្រូវរាយការណ៍មកគណៈគ្រប់គ្រងអង្គភាព ។
៩. ត្រូវចេះថែរក្សា និងមើលការទទួលខុសត្រូវលើឧបករណ៍ដែលខ្លួនកំពុងប្រើប្រាស់និងគ្រប់គ្រងសព្វថ្ងៃ ក្នុងករណីមានចេតនាធ្វើឲ្យខូចខាតលើឧបករណ៍នោះ សាមីខ្លួន ត្រូវមានកាតព្វកិច្ចចេញថ្លៃសងការខូចខាតទាំងស្រុង ។
១០. មិនអនុញ្ញាតអោយយកប័ណ្ណសារព័ត៌មាន រឺឈ្មោះអង្គភាព ប្រើប្រាស់ក្នុងរូបភាពផ្ទុយពីច្បាប់ស្តីពីរបបសារព័ត៌មានកម្ពុជា និងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន រួមទាំងច្បាប់ពាក់ព័ន្ធផ្សេងៗ ។
១១. ករណីប្រព្រឹត្តអំពីពុករលួយ ឬចំរិតទារប្រាក់ពីប្រជាពលរដ្ឋ ឬស្ថាប័នផ្សេងៗ ផ្ទុយនឹងច្បាប់ជាតិ និងអន្តរជាតិត្រូវទទួលខុសត្រូវដោយខ្លួនឯង ចំពោះមុខផ្លូវច្បាប់ អង្គភាពយើងខ្ញុំមិនទទួលខុសត្រូវឡើយ ។
១២. ការសុំឈប់សំរាក លាលែងពីការងារ ត្រូវរាយការណ៍ជូនដល់ ភាគី(ក) ដឹងជាមុនយ៉ាងហោចណាស់មុន១ខែ ហើយត្រូវប្រគល់ប័ណ្ណសារព័ត៌មាន និងសម្ភារៈឧបករណ៍បច្ចេកទេសរបស់អង្គភាព មកកាន់អង្គភាពវិញជាដាច់ខាត យ៉ាងយូរបំផុត រយៈពេល ៧ថ្ងៃ ក្រោយកាលបរិច្ឆេទនៃលិខិតសុំលាលែង របស់សាមីខ្លួននោះ ។

ករណីបុគ្គលដែលជាបុគ្គលិកខាងលើ ពុំបានគោរពនូវលក្ខខណ្ឌ **១២ចំណុច** ដែលបានរៀបរាប់ខាងលើនោះ អង្គភាពសារព័ត៌មានធីញូស៍ដេលី មានសិទ្ធបញ្ឈប់ការងារ ឬមានចំណាត់ការតាមផ្លូវច្បាប់ជាធរមាន ដោយអង្គភាពពុំជូនដំណឹង និងប្រាប់អំពីមូលហេតុជាមុនឡើយ ។

**កិច្ចសន្យានេះមានសុពលភាពគិតត្រឹមចាប់ពីថ្ងៃចុះហត្ថលេខា និងផ្តិតស្នាមមេដៃនេះតទៅ។**

ថ្ងៃ................................ខែ...................ឆ្នាំ.......... ..................ស័ក ព.ស២៥៦........

ធ្វើនៅ..........................., ថ្ងៃទី..........ខែ.........ឆ្នាំ២០...........

**ស្នាមមេដៃស្តាំ ភាគី ក** **ស្នាមមេដៃសាក្សី** **ស្នាមមេដៃស្តាំ ភាគី ខ**

**ហេង សុធីរ**